ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៨៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មការតាមដាន ត្រួតពិនិត្យ និងតម្រង់ទិស លើការសាងសង់កែលម្អនិងការអនុវត្តកិច្ចព្រមព្រៀងអភិវឌ្ឍន៍អាកាសយានដ្ឋានមូលដ្ឋាននិងអន្តរជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២៣/០២០ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មការតាមដាន ត្រួតពិនិត្យ និងតម្រង់ទិស លើការសាងសង់កែលម្អនិងការអនុវត្តកិច្ចព្រមព្រៀងអភិវឌ្ឍន៍អាកាសយានដ្ឋានមូលដ្ឋាននិងអន្តរជាតិ ដែលសរសេរជាអក្សរកាត់ថា **គ.ត.អ.** ដើម្បីធានាពង្រឹងសុវត្ថិភាពសន្តិសុខ និងធានានិរន្តរភាពនៃការអភិវឌ្ឍអាកាសយានដ្ឋានមូលដ្ឋាននិងអន្តរជាតិក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## តួនាទីនិងភារកិច្ចរបស់ គ.ត.អ.

**មាត្រា២ .-**

**គ.ត.អ.** មានតួនាទីជាសេនាធិការរបស់រាជរដ្ឋាភិបាល និងមានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យនិងផ្តល់យោបល់លើផែនការវិនិយោគសាងសង់កែលម្អអាកាសយានដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ
- ត្រួតពិនិត្យតាមដានលើការសាងសង់បន្ថែម លក្ខណៈបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធ និងការបំពាក់សម្ភារៈបច្ចេកទេស បម្រើឱ្យប្រតិបត្តិការអាកាសយានដ្ឋាន
- ចរចាជាមួយក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានលើសុពលភាពនៃកិច្ចព្រមព្រៀងវិនិយោគ ការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគ ការទូទាត់សំណង ឬការកែសម្រួលផែនការវិនិយោគតាមការណែនាំរបស់រាជរដ្ឋាភិបាល
- តាមដាន ត្រួតពិនិត្យ និងតម្រង់ទិស លើការអនុវត្តកិច្ចព្រមព្រៀងអភិវឌ្ឍន៍អាកាសយានដ្ឋានមូលដ្ឋាននិងអន្តរជាតិ ក្នុងព្រះរាជាណាចក្រកម្ពុជា
- សិក្សាលើគ្រប់ទិដ្ឋភាពនៃកិច្ចព្រមព្រៀងវិនិយោគអាកាសយានដ្ឋានទាំងអស់ ដែលរាជរដ្ឋាភិបាលបានចុះហត្ថលេខាជាមួយក្រុមហ៊ុនវិនិយោគពាក់ព័ន្ធ
- សម្របសម្រួលជាមួយភាគីពាក់ព័ន្ធលើការសាងសង់កែលម្អនិងអភិវឌ្ឍអាកាសយានដ្ឋាននិងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ
- ពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃលើការវិនិយោគរបស់ក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានមូលដ្ឋាននិងអន្តរជាតិ ដែលរាជរដ្ឋាភិបាលបានចុះហត្ថលេខា
- ត្រួតពិនិត្យបញ្ជីគណនេយ្យរបស់ក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានមូលដ្ឋាននិងអន្តរជាតិ ដើម្បីទទួលបានទិន្នន័យវិនិយោគនិងកំណត់ឱ្យបានត្រឹមត្រូវនូវស្ថានភាពហិរញ្ញវត្ថុ ព្រមទាំងការគណនាអត្រាចំណូលរបស់ក្រុមហ៊ុន ស្របតាមកិច្ចព្រមព្រៀងនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ពិនិត្យនិងតាមដានកិច្ចប្រតិបត្តិការអាជីវកម្មអាកាសយានដ្ឋានមូលដ្ឋាននិងអន្តរជាតិ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ **គ.ត.អ.** ជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

## ជំពូកទី៣
## សមាសភាពរបស់ គ.ត.អ.

**មាត្រា៣ .-**

**គ.ត.អ.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | ប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ១ រូប | អនុប្រធានប្រចាំការ |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ១ រូប | សមាជិក |
| - តំណាងក្រុមប្រឹក្សាអ្នកច្បាប់ ១ រូប | សមាជិក |

- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១ រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានពន្ធដារ ១ រូប សមាជិក
- តំណាងនិយ័តករគណនេយ្យនិងសវនកម្ម ១ រូប សមាជិក
- អគ្គនាយកបច្ចេកទេសនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក
- អគ្គនាយកប្រតិបត្តិការនិងសេវាកម្មនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តដែលមានអាកាសយានដ្ឋាន សមាជិក
- ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃអគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក។

សមាសភាពជាក់ស្តែងនៃ **គ.ត.អ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ត.អ.

**មាត្រា៤ .-**

**គ.ត.អ.** ត្រូវធ្វើការប្រជុំយ៉ាងតិច២(ពីរ)ដង ក្នុង១(មួយ)ឆ្នាំ។ ក្នុងករណីចាំបាច់ **គ.ត.អ.** អាចប្រជុំជាវិសាមញ្ញ។ អនុប្រធាននិងសមាជិក **គ.ត.អ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានណាមួយដឹកនាំប្រជុំជំនួសបាន។

**មាត្រា៥ .-**

**គ.ត.អ.** អាចអញ្ជើញបុគ្គលដែលមានជំនាញ ឬតំណាងក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធក្រៅពីសមាសភាពដូចមានចែងក្នុងមាត្រា៣នៃអនុក្រឹត្យនេះ ចូលរួមប្រជុំដើម្បីផ្តល់យោបល់ឬសេចក្តីបំភ្លឺបាន។

**មាត្រា៦ .-**

**គ.ត.អ.** មានអគ្គនាយកដ្ឋានបច្ចេកទេសនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល បំពេញមុខងារជាលេខាធិការដ្ឋាន។ លេខាធិការដ្ឋាន **គ.ត.អ.** មានទីតាំងស្ថិតនៅរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងមានសិទ្ធិប្រើមន្ត្រីនៅក្នុងនាយកដ្ឋានពាក់ព័ន្ធនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល តាមការចាំបាច់។

សមាសភាព តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាននៃ **គ.ត.អ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ត.អ.**។

**មាត្រា៧ .-**

**គ.ត.អ.** មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធានរបស់ គ.ត.អ.

**មាត្រា៨ .-**

**គ.ត.អ.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**គ.ត.អ.** មានសិទ្ធិទទួល និងចាត់ចែងប្រើប្រាស់តាមនីតិវិធីដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននូវប្រភពធនធានដែលបានមកពីដៃគូអភិវឌ្ឍនិងប្រភពស្របច្បាប់ផ្សេងទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៣៦ សសរ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងទុនវិនិយោគរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ(SCA) សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៣៧ សសរ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ការសាងសង់អាកាសយានដ្ឋានអន្តរជាតិសៀមរាប និងការសាងសង់អាកាសយានដ្ឋានដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៨ រោច ខែ ស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ